**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រ.ក/លេខ ០៦.០៩០/០៨ គ.ជ.ប/អគ.ពស**

ភ្នំពេញ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៨

# ស្ថានីយវិទ្យុសំបុកឃ្មុំ FM 105 MHz មានម៉ោងសម្រាប់ជួលឱ្យគណបក្សនយោបាយធ្វើការផ្សព្វផ្សាយគោលនយោបាយក្នុងពេលឃោសនាបោះឆ្នោត

ស្ថានីយវិទ្យុសំបុកឃ្មុំ **FM 105 MHz** មានម៉ោងសរុបចំនួន ៣៣០នាទី ក្នុង ១ថ្ងៃ សម្រាប់លក់ឱ្យគណបក្សនយោបាយ ដើម្បីផ្សព្វផ្សាយគោលនយោបាយគណបក្សក្នុងពេលឃោសនាបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី៤ ឆ្នាំ២០០៨ ដោយលក់ក្នុងតម្លៃ **$2000** (ពីរពាន់ដុល្លារអាមេរិក) សម្រាប់រយៈពេល ៣០នាទី ។

យោងតាមលិខិតជូនដំណឹងរបស់វិទ្យុនេះ ចុះថ្ងៃទី ១១ ខែមិថុនា ឆ្នាំ២០០៨ បានឱ្យដឹងថា ចំនួនម៉ោងខាងលើនេះអាចចែកលក់ឱ្យគណបក្សនយោបាយទាំង ១១ គឺគណបក្សនយោបាយនីមួយៗមាន ៣០ នាទី ក្នុង ១ថ្ងៃ សម្រាប់ទិញម៉ោងនេះ ដើម្បីធ្វើការឃោសនាពីកម្មវិធីនយោបាយរបស់ខ្លួន ក្នុងអំឡុងពេលឃោសនាដែលចាប់ពីថ្ងៃទី ២៦ ខែមិថុនា រហូតដល់ថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ២០០៨ ។

តាមរយៈលិខិតរបស់វិទ្យុសំបុកឃ្មុំ **FM 105 MHz** បានឱ្យដឹងថា អ្នកគ្រប់គ្រងវិទ្យុនេះបានសរសេរលិខិតជូនដំណឹងទៅគ្រប់គណបក្សចំនួន ១១ ដែលចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោត ឆ្នាំ២០០៨ តាំងពីថ្ងៃទី ៦ ខែមិថុនា ឆ្នាំ២០០៨ អំពីការជួលម៉ោងផ្សាយកម្មវិធីនយោបាយ ។ ហើយក្នុងលិខិតជូនដំណឹងនេះបានឱ្យដឹងទៀតថា រហូតមកដល់ពេលនេះមានគណបក្សនយោបាយចំនួន ៥ ហើយ គឺ គណបក្សសម រង្ស៊ី, គណបក្សសិទ្ធិមនុស្ស , គណបក្សនរោត្តម រណឫទ្ធិ , គណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ ដែលបានចុះឈ្មោះសុំជួល ។

សូមបញ្ជាក់ថា រហូតមកដល់ពេលនេះ គ.ជ.ប ទើបតែទទួលបានសេចក្តីជូនដំណឹងរបស់ស្ថានីយវិទ្យុចំនួន ៣ ប៉ុណ្ណោះ ស្តីពីការលក់ម៉ោង ឬជួលម៉ោងឱ្យគណបក្សនយោបាយធ្វើការឃោសនាបោះឆ្នោត គឺស្ថានីយវិទ្យុមហានគរ **FM 93.5 MHz** ស្ថានីយវិទ្យុសុវណ្ណភូមិ **FM 104 MHz** និងស្ថានីយវិទ្យុសំបុកឃ្មុំ **FM 105 MHz** ។

ព័ត៌មានបន្ថែម សូមទំនាក់ទំនងទូរស័ព្ទលេខ : ០២៣ ២១៤ ៣៧៤ / ០១២ ៨៥៩ ០១៨ E-mail: necinfo@forum.org.kh,
Website: www.necelect.org.kh, Web-site: www.voterlist.org.kh